# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**

**លេខ...០៤/១៧..ន/ក**

## សេចក្តីប្រកាសព័ត៌មាន
## អ្នកនាំពាក្យ ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា

អ្នកនាំពាក្យក្រសួងការពារជាតិ សូមប្រកាសច្រាលចោល និងថ្កោលទោសសេចក្តីថ្លែងការណ៍របស់អង្គការខុមហ្វ្រែល និងសមាគម អង្គការសង្គមស៊ីវិលនៅកម្ពុជា នៃបន្ទប់ស្ថានការណ៍សម្រាប់បោះឆ្នោត គឺមានចេតនាញុះញង់ និងលាបពណ៌មកលើកងយោធពលខេមរភូមិន្ទ និងជាការប្រមាថមាក់ងាយដល់កិត្តិយស តួនាទី ភារកិច្ចរបស់កងយោធពលខេមរភូមិន្ទ។

កងយោធពលខេមរភូមិន្ទ បានយល់ច្បាស់អំពីច្បាប់បោះឆ្នោត និងតួនាទី ភារកិច្ចរបស់ខ្លួនក្នុងការអនុវត្តន៍តាមសេចក្តីណែនាំរួមស្តីអំពីការពង្រឹងវិន័យ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនចូលរួមក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អណត្តិទី៤ ឆ្នាំ២០១៧ របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនចាំបាច់មានអង្គការខុមហ្វ្រែល និងសមាគម អង្គការសង្គមស៊ីវិលនៅកម្ពុជាមកណែនាំនោះទេ។ ក្រសួងការពារជាតិចាត់ទុកថាការថ្លែងការណ៍ និងវោហាសាសន៍ទាំងឡាយមកលើ តួនាទីកងយោធពលខេមរភូមិន្ទហាក់ដូចជាមានចេតនាអ្វីមួយទៅអនាគត។

សេចក្តីថ្លែងការណ៍ដោយបង្កាប់បញ្ហាមកលើកងយោធពលខេមរភូមិន្ទ គឺជាការរំលោភដ៏ធ្ងន់ធ្ងរលើកងយោធពលខេមរភូមិន្ទ ដែលមិនអាចទទួលយកបានឡើយ។

ក្រសួងការពារជាតិសូមជម្រាបជូន មតិជាតិ និងអន្តរជាតិឲ្យបានជ្រាបថា សកម្មភាព និងអនុសាសន៍របស់មន្ត្រីជាន់ខ្ពស់កងយោធពលខេមរភូមិន្ទកន្លងមក មិនប៉ះពាល់ដល់ដំណើរការបោះឆ្នោតនោះទេ។ វាគឺជាការជំរុញដល់ការការពារសន្តិសុខ សុវត្ថិភាព សម្រាប់ការបោះឆ្នោតនៅកម្ពុជា ដោយមិនអនុញ្ញាតឲ្យជនណាឆ្លៀតយកឱកាសនេះ ដើម្បីបង្កអសន្តិសុខ បំផ្លាញសន្តិភាពរបស់កម្ពុជាឡើយ ផ្ទុយទៅវិញការលើកឡើងរបស់មន្ត្រីជាន់ខ្ពស់កងយោធពលខេមរភូមិន្ទ គឺជាការតម្រង់ឆ្ពោះទៅរកអ្នក ដែលព្យាយាមបំផ្លាញសន្តិភាព និងការបង្កើតបដិវត្តន៍ពណ៌នៅកម្ពុជា។

កងយោធពលខេមរភូមិន្ទ មិនគាំទ្រចំពោះទង្វើខុសច្បាប់ឡើយ មិនមែនត្រឹមតែកងទ័ពនោះទេ ក្នុងករណីមានជនណាមួយដែលប្រព្រឹត្តខុសនឹងច្បាប់ គ.ជ.ប ពលរដ្ឋកម្ពុជាគ្រប់រូប មានសិទ្ធប្តឹងតវ៉ាទៅគ្រប់ស្ថាប័នមានសមត្ថកិច្ចរបស់ជាតិ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ខែឧសភា ឆ្នាំ ២០១៧*

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤ អ៊ីម៉ែល៖ generalsec@mod.gov.kh